ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# ទស្សនវិស័យ មុខរបរ និងការងារ

## តម្រូវការជំនាញ និងការងារសម្រាប់យុវជន



លេខ៦ ឆមាសទី២ ឆ្នាំ២០២៦

សម្រាប់ការដាក់ឯកសារយោង៖ អ៊ុំ ច័ន្ទមនោ, អ៊ុំ សូម៉ារ៉ា, គី សេរីវ៉ុធ, ប៊ុន បូពិត, ថា ចាន់ថន, អេង ច័ន្ទសេរីរតន៍ ។ ទស្សនវិស័យមុខរបរ និងការងារ៖ តម្រូវការជំនាញ និងការងារសម្រាប់យុវជន ឆមាសទី២ ឆ្នាំ២០២៦។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, រាជធានីភ្នំពេញ ប្រទេសកម្ពុជា។

# អារម្ភកថា

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងនាមជាសេនាធិការរបស់រាជរដ្ឋាភិបាលកម្ពុជា តែងតែប្រកាន់ខ្ជាប់នូវស្មារតីទទួលខុសត្រូវខ្ពស់ក្នុងការជំរុញរបៀបវារៈយុទ្ធសាស្ត្រជាតិ ដោយចូលរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ តាមរយៈការអភិវឌ្ឍមូលធនមនុស្ស ការធ្វើទំនើបកម្មនិងលើកកម្ពស់ភាពធន់នៃទីផ្សារការងារ និងការបង្កើនផលិតភាពការងារ។ នៅក្នុងបរិបទនៃការរីកចម្រើនយ៉ាងឆាប់រហ័សផ្នែកបច្ចេកវិទ្យា និងការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ច និងទីផ្សារការងារ ការដាក់ចេញនូវគោលនយោបាយទីផ្សារការងារ គឺជាគន្លងដ៏សំខាន់មួយឆ្ពោះទៅរកការធ្វើទំនើបកម្មប្រព័ន្ធទីផ្សារការងារកម្ពុជា ព្រមទាំងការលើកកម្ពស់ការគាំពារសង្គម និងពង្រឹងភាពប្រកួតប្រជែងទាំងនៅកម្រិតជាតិ និងអន្តរជាតិ។ ការធ្វើបច្ចុប្បន្នភាពព័ត៌មានទីផ្សារការងារប្រកបដោយភាពគ្រប់ជ្រុងជ្រោយ និងទាន់ពេលវេលា គឺជាសសរស្តម្ភដែលមិនអាចខ្វះបានក្នុងការរៀបចំផែនការយុទ្ធសាស្ត្រ ដើម្បីបង្កើត រក្សា និងបង្កើនការងារទាំងបរិមាណ និងគុណភាព ជាពិសេសសម្រាប់យុវជន កម្មករនិយោជិតទាំងក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ សំដៅសម្រេចឱ្យបាននូវចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។

ផ្អែកលើបេសកកម្មនេះ ចាប់តាំងពីឆ្នាំ២០២៤ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបោះពុម្ពផ្សាយប្រកបដោយជោគជ័យនូវឯកសារ «**ទស្សនវិស័យមុខរបរ និងការងារ**» ចំនួន ៥លេខ រួចមកហើយ។ សម្រាប់ឆមាសទី២ ឆ្នាំ២០២៦ នេះ ក្រសួងមានមោទនភាពក្នុងការបន្តផ្សព្វផ្សាយឯកសារ «**ទស្សនវិស័យមុខរបរ និងការងារ**» **លេខ៦** ដែលត្រូវបានរៀបចំឡើងដោយយកចិត្តទុកដាក់បំផុតស្របតាមការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ច និងទីផ្សារការងារបច្ចុប្បន្ន ហើយឯកសារនេះក៏ត្រូវបានចងក្រងឡើងសម្រាប់សិស្ស-និស្សិត យុវជន អ្នកស្វែងរកការងារ អ្នកផ្តល់ការបណ្តុះបណ្តាល និងនិយោជកសម្រាប់បម្រើជាមគ្គុទ្ទេសក៍ជាក់ស្តែង និងច្បាស់លាស់ ក្នុងការតម្រង់ទិសជណ្តើរអាជីព ការរៀបចំផែនការបណ្តុះបណ្តាល និងការអភិវឌ្ឍជំនាញឱ្យឆ្លើយតបនឹងតម្រូវការទីផ្សារការងារជាក់ស្តែង ព្រមទាំងចូលរួមលើកកម្ពស់ផលិតភាព និងវឌ្ឍនភាពសេដ្ឋកិច្ច-សង្គមកម្ពុជាប្រកបដោយចីរភាព និងបរិយាបន្ន។ ការចេញផ្សាយលើកនេះ ផ្តល់នូវការវិភាគស៊ីជម្រៅលើនិន្នាការមុខរបរដែលកំពុងលេចឡើង ដោយផ្តោតគោលដៅលើការបង្ហាញឱ្យឃើញច្បាស់នូវជណ្តើរអាជីព នៅក្នុងអនុវិស័យដែលកំពុងមានតម្រូវការការងារខ្ពស់ សំដៅផ្តល់ព័ត៌មានគ្រប់ជ្រុងជ្រោយដល់យុវជនកម្ពុជាក្នុងការផ្សារភ្ជាប់មុខជំនាញសិក្សា ឬ បណ្តុះបណ្តាលរបស់ពួកគេ ទៅនឹងតថភាពជាក់ស្តែងនៃតម្រូវការទីផ្សារការងារ។

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ជឿជាក់យ៉ាងមុតមាំថា ឯកសារនេះនឹងក្លាយជាធនធានដ៏មានសារៈសំខាន់សម្រាប់គ្រប់ភាគីពាក់ព័ន្ធទាំងអស់ ក្នុងការប្រើប្រាស់សំដៅរួមចំណែកជំរុញការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកម្ពុជា ឱ្យកាន់តែមានសក្តានុពល និងប្រកបដោយបរិយាបន្ន។ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅតែបន្តប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការធ្វើទំនើបកម្ម និងផ្សព្វផ្សាយព័ត៌មានទីផ្សារការងារ ដើម្បីធានាថាយុវជនកម្ពុជាគ្រប់រូបមានឱកាសទទួលបានការងារសមរម្យ មានជំនាញនិងផលិតភាពការងារខ្ពស់ សំដៅប្រែក្លាយជាមូលធនមនុស្សរបស់កម្ពុជាទាំងពេលបច្ចុប្បន្ន និងអនាគត។

ថ្ងៃព្រហស្បតិ៍ ១រោច ខែទុតិយាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ២០២៦

រដ្ឋមន្ត្រី

ហេង សួរ

## មាតិកា

ផ្នែកទី ១ សេដ្ឋកិច្ច និងទីផ្សារការងារ ឆ្នាំ២០២៦

ផ្នែកទី ២ ជំនាញដែលមានតម្រូវការនាពេលអនាគត

ផ្នែកទី ៣ មុខរបរ និងការងារតាមអនុវិស័យសំខាន់ៗ

ផ្នែកទី ៤ ការចាប់យកឱកាសបណ្ដុះបណ្ដាល ប្រឹក្សាយោបល់ការងារ និងថែទាំសុខភាព

## ផ្នែកទី១៖ សេដ្ឋកិច្ច និងទីផ្សារការងារឆ្នាំ ២០២៦

សម្រាប់ឆ្នាំ២០២៦ ទីផ្សារការងារក្នុងស្រុករំពឹងថានឹងបន្តបង្ហាញពីភាពធន់ តាមរយៈការរក្សាបាននូវស្ថិរភាព និងកំណើនវិជ្ជមាននៃចំនួនការងារ ដែលក្នុងនោះអ្នកមានការងារធ្វើត្រូវបានព្យាករកើនប្រមាណ ៣១,៦ម៉ឺននាក់ ឬស្មើនឹងអត្រាកំណើន ៣,០% ធៀបនឹងឆ្នាំ២០២៥។ កំណើននេះបានធ្វើឱ្យការងារសរុបទូទាំងប្រទេសកើនដល់ ១១,០៣លានកន្លែង ក្នុងនោះ៖ វិស័យសេវាកម្មមាន ៤,៩៨លានកន្លែង ឧស្សាហកម្ម ៣,២៨លានកន្លែង និង កសិកម្ម ២,៧៧លានកន្លែង។ ទិន្នន័យនេះបង្ហាញឱ្យឃើញពីនិន្នាការនៃការធ្វើពិពិធកម្មសេដ្ឋកិច្ច ដោយងាកចេញពីការពឹងផ្អែកលើកសិកម្ម ឆ្ពោះទៅរកការពង្រីកវិស័យឧស្សាហកម្ម និងសេវាកម្ម។

រូបភាពទី១៖ ចំនួនអ្នកមានការងារធ្វើ និងកំណើនការងារតាមវិស័យ (ឆ្នាំ២០២៥ - ២០២៦)




### សម្គាល់បច្ចេកទេសសម្រាប់ ការព្យាករចំនួនការងារ

- កំណើនចំនួនការងារ ត្រូវបានព្យាករផ្អែកលើសូចនាករសំខាន់ពីរគឺ៖ (១) កំណើនតាមវិស័យដែលផ្ដល់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង (២) ការគណនាមេគុណការងារតាមវិស័យ (Employment Coefficient = Workers/Output)។ ការគណនានេះប្រើប្រាស់វិធីសាស្ត្រ Auto-Regressive Integrated Moving Average (ARIMA)[១] និង Compound Annual Growth Rate (CAGR)[២] ដោយយោងតាមទិន្នន័យអង្កេតសេដ្ឋកិច្ច-សង្គមកិច្ច ឆ្នាំ២០០០-២០២៣ និងទិន្នន័យបឋមនៃអង្កេតកម្លាំងពលកម្មឆ្នាំ២០២៥។

១) Ky, S. (2023). Labour demand forecasting: The case of Cambodia. *Bulletin of Applied Economics*, *10*(2), 89–105.

២) Vinitha, Y., Chanikya, G., Suryanshu, & Maiti, S. (2023). Does growth of gross state domestic product can manage unemployment in India? A state-level analysis. *International Journal for Multidisciplinary Research*, *5*(5), 1–14.

រូបភាពទី២៖ បម្រែបម្រួលចំនួនសហគ្រាស ក្រុមហ៊ុន រោងចក្រ
និងកម្មករនិយោជិតក្នុងប្រព័ន្ធ គិតត្រឹម ឆមាសទី១ ឆ្នាំ២០២៦




ក្នុងឆមាសទី១ ឆ្នាំ២០២៦ កម្ពុជាបានរក្សាអត្រាកំណើនការនាំចេញសរុបប្រមាណ ១៧,៩% ប្រៀបធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំ២០២៥ ខណៈដែលសហគ្រាស ក្រុមហ៊ុន រោងចក្រក្នុងប្រព័ន្ធសរុបបានកើនឡើង ៨៤៥ កន្លែង ដែលភាគច្រើនស្ថិតក្នុងអនុវិស័យក្រៅពីកាត់ដេរ។ កំណើននេះបានជំរុញឱ្យកម្លាំងពលកម្មក្នុងប្រព័ន្ធកើនឡើងជាង ១៦,៨ម៉ឺននាក់ បន្ថែមទៀត។ កំណើនដ៏រឹងមាំនៃអនុវិស័យក្រៅកាត់ដេរ គឺជាសញ្ញាវិជ្ជមាន ដែលឆ្លុះបញ្ចាំងពីវឌ្ឍនភាពនៃការធ្វើពិពិធកម្មសេដ្ឋកិច្ច ក៏ដូចជាការរីកចម្រើននៃទំនុកចិត្តធុរកិច្ច និងការវិនិយោគរបស់កម្ពុជា។

ទោះបីជាកម្ពុជារងនូវកម្មវិបាកផ្ទួនៗគ្នាជាអវិជ្ជមានចំនួន ៣ធំៗ ដូចជា៖ ការកើនឡើងថ្លៃប្រេងឥន្ធនៈ ពិសេសមកលើវិស័យដែលពឹងផ្អែកលើប្រេង ជាកត្តាផលិតកម្ម; កម្មវិបាក និងឥទ្ធិពលសាយភាយពីបញ្ហាព្រំដែនកម្ពុជា-ថៃ; និង ផលប៉ះពាល់ក្នុងរយៈពេលខ្លីនៃការបង្ក្រាបការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ក៏ចំនួនអ្នកមានការងារធ្វើក្នុងវិស័យឧស្សាហកម្មនៅតែសម្រេចបានអត្រាកំណើន ៧,៩%។ កំណើននេះកើតចេញពីការរក្សាបាននូវភាពរឹងមាំក្នុងអនុវិស័យកាត់ដេរ ដែលនឹងបន្តកើនឡើង ៧,៧% ខណៈអនុវិស័យកម្មន្តសាលក្រៅពីកាត់ដេរត្រូវបានរំពឹងថានឹង

មានកំណើនប្រមាណ ១៧,០%។ កំណើននេះនៅតែបង្ហាញពីសញ្ញាវិជ្ជមាន និងស្ថិរភាពការងារជូនកម្មករនិយោជិតរាប់លាននាក់ ព្រមទាំងបង្កើតកាលានុវត្តភាពថ្មីៗ សម្រាប់កម្លាំងពលកម្មជំនាញក្នុងខ្សែច្រវាក់ផលិតកម្ម ដែលមានតម្លៃបន្ថែមខ្ពស់ ដែលជាគន្លឹះសំខាន់ក្នុងការលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាពលរដ្ឋ។

បន្ថែមពីនេះបញ្ញាសិប្បនិម្មិត (AI) បានវិវត្តពីឧបករណ៍ជំនួយការងារធម្មតា មកជាហេដ្ឋារចនាសម្ព័ន្ធស្នូលក្នុងគ្រប់វិស័យ។ នៅក្នុងប្រទេសកម្ពុជា ការប្រើប្រាស់បញ្ញាសិប្បនិម្មិត ក្នុងការវិភាគទិន្នន័យ ការគ្រប់គ្រងខ្សែច្រវាក់ផ្គត់ផ្គង់ និងស្វ័យប្រវត្តិកិច្ចការប្រចាំថ្ងៃ កំពុងជួយកាត់បន្ថយចំណាយប្រតិបត្តិការយ៉ាងច្រើនសម្រាប់សហគ្រាសធុនតូច និងធុនមធ្យម ។ បច្ចេកវិទ្យានេះត្រូវបានគេព្យាករថានឹងអាចជួយជំរុញទំហំសេដ្ឋកិច្ចកម្ពុជាបន្ថែមពី ៥% ទៅ ១០% នៃផលិតផលក្នុងស្រុកសរុប ត្រឹមឆ្នាំ២០៣០ (UNESCO, ២០២៦)។

បរិបទសកលភាវូបនីយកម្ម និងការផ្លាស់ប្តូរឆ្ពោះទៅរកសេដ្ឋកិច្ចបៃតង និងឌីជីថល បានធ្វើឱ្យ «សមត្ថភាពបត់បែន» និង «ជំនាញវិភាគនិងដោះស្រាយបញ្ហា» ក្លាយជាតម្រូវការចាំបាច់ដែលមិនអាចខ្វះបាន។ និន្នាការនេះទាមទារឱ្យមានការរៀបចំតម្រង់ទិសយុវជនយ៉ាងច្បាស់លាស់ ដើម្បីឱ្យពួកគេអាចចាប់យកជំនាញដែលឆ្លើយតបនឹងទីផ្សារការងារនាពេលអនាគត (ពិសេសជំនាញពាក់ព័ន្ធនឹងថាមពលកកើតឡើងវិញ និងការវិភាគទិន្នន័យ)។

## ផ្នែកទី២៖ តម្រូវការជំនាញសម្រាប់ពេលបច្ចុប្បន្ន និងអនាគត

តម្រូវការជំនាញនាពេលបច្ចុប្បន្ន និងអនាគតរបស់កម្ពុជាកំពុងមានភាពសម្បូរបែប ដោយផ្លាស់ប្តូរពីជំនាញផ្តោតលើផលិតកម្មក្នុងឧស្សាហកម្មដែលមានស្រាប់ និងឧស្សាហកម្មផលិតកម្មធុនស្រាល ទៅជាជំនាញបច្ចេកទេស ឌីជីថល បៃតង និងជំនាញដែលមានតម្លៃបន្ថែមខ្ពស់ជាងមុន។

ក្នុងរយៈពេលខ្លី (០-៣ ឆ្នាំ) តម្រូវការផ្តោតសំខាន់លើជំនាញកម្រិតខ្ពស់ និងកម្រិតមធ្យម រួមមាន៖ គណនេយ្យ និងពន្ធដារ, ការគ្រប់គ្រង និងរដ្ឋបាល, ស្ថាបត្យកម្ម និងការរៀបចំទីក្រុង, បច្ចេកវិទ្យាការពារបរិស្ថាន, កម្មវិធីកុំព្យូទ័រ និងកម្មវិធីទូរស័ព្ទ, ច្បាប់, ការកែច្នៃអាហារ, វាយនភណ្ឌ, និងផលិតកម្មដំណាំ និងសត្វ ដែលឆ្លុះបញ្ចាំងពីសារៈសំខាន់នៃឧស្សាហកម្មដែលមានស្រាប់ និងឧស្សាហកម្មគាំទ្រ។ ក្នុងរយៈពេលមធ្យម (៣-៥ ឆ្នាំ) តម្រូវការទីផ្សារការងារនឹងត្រូវបានផ្លាស់ប្តូរឆ្ពោះទៅរកជំនាញតម្រង់ទិសឧស្សាហកម្ម និងបច្ចេកវិទ្យាកាន់តែច្រើន ដូចជា៖ បញ្ញាសិប្បនិម្មិត, អេឡិចត្រូនិក និងស្វ័យប្រវត្តិកម្ម, ការរចនា និងការគ្រប់គ្រងមូលដ្ឋានទិន្នន័យ និងបណ្តាញ, មេកានិក និងជាងលោហៈ, អគ្គិសនី និងថាមពល, បច្ចេកវិទ្យាវិនិច្ឆ័យរកកំហុស, និងសុវត្ថិភាពការងារ។ ក្នុងរយៈពេលវែង (៥-១០ ឆ្នាំ) តម្រូវការខ្លាំងបំផុតគឺផ្តោតលើវិស័យដែលមានជំនាញកម្រិតខ្ពស់ ពាក់ព័ន្ធនឹងឧស្សាហកម្មយុទ្ធសាស្ត្ររួមមាន៖ ការគ្រប់គ្រងសំណល់, វិស្វកម្មគីមី, វិស្វកម្មមេកានិក, បច្ចេកវិទ្យាមន្ទីរពិសោធន៍, បច្ចេកវិទ្យាការពារបរិស្ថាន, និងស្វ័យប្រវត្តិកម្ម។ សរុបមក យុទ្ធសាស្ត្រអភិវឌ្ឍន៍ជំនាញរបស់កម្ពុជា គួរបញ្ចូលគ្នារវាងការលើកកម្ពស់ភ្លាមៗ នូវជំនាញផលិតកម្មជាក់ស្តែង និងជំនាញគាំទ្រផលិតកម្ម ជាមួយនឹងការវិនិយោគទាន់ពេលវេលាលើជំនាញបច្ចេកទេសកម្រិតខ្ពស់ ឌីជីថល វិស្វកម្ម និងជំនាញបៃតង ដែលចាំបាច់សម្រាប់ការផ្លាស់ប្តូររូបរាងឧស្សាហកម្ម ក្រោមវិស័យឧស្សាហកម្មអាទិភាព។

## រូបភាពទី ៣៖ តម្រូវការជំនាញបច្ចុប្បន្ន និងនាពេលអនាគត សម្រាប់វិស័យឧស្សាហកម្មអាទិភាព




*សម្គាល់៖ មុខជំនាញទាំង ៨៦ នេះ ត្រូវបានវិភាគ និងព្យាករណ៍ចេញពីមុខរបរចំនួន ១៥១ ដែលមានតម្រូវការក្នុងទីផ្សារការងារក្នុងរយៈពេលខ្លី (០-៣ ឆ្នាំ), មធ្យម (៣-៥ ឆ្នាំ) និងវែង (៥-១០ ឆ្នាំ) ទៅតាមកម្រិតជំនាញ និងគុណវុឌ្ឍិ។ បន្ថែមពីនេះ វិស័យដែលត្រូវបានយកមកធ្វើការវិភាគរួមមាន៖ កសិឧស្សាហកម្ម និងកែច្នៃម្ហូបអាហារ, ឧស្សាហកម្មកែច្នៃឈើ និងគ្រឿងសង្ហារិម និងឧស្សាហកម្មកាត់ដេរ, ឧស្សាហកម្មអេឡិចត្រូនិក, ឧស្សាហកម្មយានយន្ត និងឧស្សាហកម្មផលិតបរិក្ខារវេជ្ជសាស្ត្រ, ឧស្សាហកម្មនាវាចរណ៍, ឧស្សាហកម្មគីមីឥន្ធនៈ, ឧស្សាហកម្មបន្ទះឈើ, និងឧស្សាហកម្មការពារជាតិ និងបច្ចេកវិទ្យាប្រើប្រាស់ទ្វេទិស, ឧស្សាហកម្មកែច្នៃសំណល់, សេវាកម្មឌីជីថលដែលគាំទ្រដោយ AI, ថាមពលបៃតង, ឡូជីស្ទីក និងហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងឧស្សាហកម្មទេសចរណ៍។*

*ប្រភព៖ អង្កេតទស្សនវិស័យមុខរបរ និងការងារ, របាយការណ៍ស្ដីពីកិច្ចសហការរវាងមនុស្សនិងម៉ាស៊ីនក្នុងប្រតិបត្តិការឧស្សាហកម្មឆ្នាំ២០២៦ របស់វេទិកាសេដ្ឋកិច្ចពិភពលោក (WEF), របាយការណ៍ស្ដីពីអនាគតនៃការងារឆ្នាំ២០២៥ (WEF), របាយការណ៍ប្រព័ន្ធកសិកម្ម-ចំណីអាហាររបស់អង្គការ FAO, របាយការណ៍ខ្សែច្រវាក់តម្លៃសកលរបស់មជ្ឈមណ្ឌលអាស៊ាន-ជប៉ុន, របាយការណ៍ខ្សែច្រវាក់តម្លៃយានយន្ត/ការសាងសង់នាវា/ semiconductor របស់អង្គការ OECD, របាយការណ៍ថាមពលកកើតឡើងវិញ និងគីមីឥន្ធនៈរបស់ទីភ្នាក់ងារ IEA, របាយការណ៍សេដ្ឋកិច្ចឌីជីថល/AI កម្ពុជាកម្ម និងសេដ្ឋកិច្ចវិលជុំរបស់ធនាគារពិភពលោក, និងប្រភពឯកសារឧបករណ៍វេជ្ជសាស្ត្ររបស់អង្គការ WHO/GMDN។*

***កំណត់សម្គាល់បច្ចេកទេស៖***

*ម៉ាទ្រីសតម្រូវការជំនាញត្រូវបានរៀបចំឡើងដោយផ្សារភ្ជាប់ឧស្សាហកម្មអាទិភាពរបស់កម្ពុជា ទៅនឹងមុខរបរ និងចំណាត់ថ្នាក់ជំនាញ ដែលអាចប្រៀបធៀបបានជាអន្តរជាតិ។ ជំហានទី១ មុខរបរពាក់ព័ន្ធនឹងឧស្សាហកម្មនីមួយៗ ត្រូវបានកំណត់អត្តសញ្ញាណ និងដាក់កូដដោយប្រើប្រាស់ប្រព័ន្ធ ISCO-08 ដោយក្នុងនោះកម្រិតជំនាញត្រូវបានទាញចេញពីកម្រិតជំនាញរបស់ ISCO។ ជំហានទីពីរ មុខរបរនីមួយៗ ត្រូវបានភ្ជាប់ទៅកាន់កូដជំនាញ ISCED-F 2013 ហើយក្នុងករណីចាំបាច់ ជំនាញដែលមិនស្ថិតក្នុងប្រព័ន្ធ ISCED ត្រូវបានបន្ថែម ដោយទាញយកមកពីរបាយការណ៍ផ្លូវការ ឬឯកសារស្រាវជ្រាវផ្សេងៗ។ ជំហានទីបី សន្ទស្សន៍មុខរបរពីទិន្នន័យនិន្នាការមុខរបរនេះត្រូវបានបញ្ចូលទៅក្នុងការប៉ាន់ប្រមាណនៃតម្រូវការជំនាញ។ ជាចុងក្រោយ ជំនាញទាំងនោះត្រូវបានបូកសរុបបញ្ចូលគ្នាតាមក្រុមឧស្សាហកម្ម និងកម្រិតជំនាញ ISCO ដើម្បីកំណត់អត្តសញ្ញាណជំនាញណាខ្លះដែលកំពុងមានតម្រូវការនាពេលបច្ចុប្បន្ន ឬនឹងមានភាពស្របទៅនឹងការផ្លាស់ប្ដូរទម្រង់ឧស្សាហកម្មរបស់កម្ពុជា។*

## ផ្នែកទី៣៖ មុខរបរ និងការងារតាមអនុវិស័យសំខាន់ៗ

ទីផ្សារការងារកម្ពុជាកំពុងផ្លាស់ប្តូរយ៉ាងខ្លាំងឆ្ពោះទៅរកសេដ្ឋកិច្ចផ្អែកលើជំនាញ និងមានតម្លៃបន្ថែមខ្ពស់។ ការផ្លាស់ប្តូរសេដ្ឋកិច្ចយ៉ាងឆាប់រហ័សនេះត្រូវបានជំរុញដោយអនុវិស័យសំខាន់ៗចំនួន ១៤ ជាមួយនឹងប្រភេទផលិតកម្ម ឧស្សាហកម្ម ដូចជា វាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប (GFT) រួមជាមួយនឹងផលិតកម្មគ្រឿងបង្គុំអេឡិចត្រូនិច, អគ្គិសនី, ផ្គុំ និងដំឡើងយានយន្ត។

សេដ្ឋកិច្ចសកល ឆ្នាំ២០២៦ ត្រូវបានព្យាករថានឹងកើនឡើងក្នុងអត្រាមធ្យម ៤,២% ចំពេលមានភាពស្រាកស្រាន្តនៃសម្ពាធពន្ធគយរបស់សហរដ្ឋអាមេរិក និងការវិនិយោគដ៏រឹងមាំលើបញ្ញាសិប្បនិម្មិត។ ចក្ខុវិស័យនេះត្រូវបានកំណត់ដោយ ការបន្តភាពមិនច្បាស់លាស់នៃភូមិសាស្ត្រនយោបាយ ការធ្លាក់ចុះនៃពាណិជ្ជកម្មអន្តរជាតិ និងលក្ខខណ្ឌហិរញ្ញវត្ថុតឹងតែង។

នៅក្នុងប្រទេសកម្ពុជា ទោះបីជាសក្តានុពលក្នុងតំបន់ និងពិភពលោកមានកាលានុវត្តភាពថ្មីក៏ដោយ ក៏ការត្រៀមលក្ខណៈត្រូវបន្តដោយប្រុងប្រយ័ត្ន។ កំណើនការងារត្រូវបានរំពឹងថានឹងផ្តោតលើសេវាកម្ម និងកម្មន្តសាលដែលមានជំនាញ ជាជាងការពង្រីកវិសាលភាពទូលំទូលាយលើគ្រប់វិស័យ។ និន្នាការនេះតម្រូវឱ្យមានការបង្កើតក្របខណ្ឌគុណវុឌ្ឍិ និងគន្លងអាជីពច្បាស់លាស់ ដើម្បីណែនាំយុវជនក្នុងការទទួលបានជំនាញដែលបំពេញតាមតម្រូវការទីផ្សារការងារនាពេលបច្ចុប្បន្ន និងអនាគត។

ក្នុងរូបភាពទី ៤ ទីផ្សារការងារកម្ពុជានៅឆ្នាំ២០២៦ ត្រូវបានរំពឹងថានឹងមានការផ្លាស់ប្តូរយ៉ាងសំខាន់ ដោយពឹងផ្អែកកាន់តែខ្លាំងឡើងលើកម្លាំងពលកម្មជំនាញ និងបច្ចេកទេស ដើម្បីជំរុញផលិតភាពសេដ្ឋកិច្ច។ កម្មករនិយោជិតជំនាញ ព្រមទាំងការីម៉ាស៊ីន និងផ្គុំដំឡើង (ចំណាត់ថ្នាក់ ISCO ក្រុមទី៧ និងទី៨) ត្រូវបានព្យាករថានឹងមានតម្រូវការខ្ពស់ជាងគេបំផុត ដោយឈានដល់ប្រមាណជាង ៣២ម៉ឺនកន្លែង ដែលជំរុញជាចម្បងដោយអនុវិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប (GFT) ព្រមទាំងអនុវិស័យកម្មន្តសាលផ្សេងៗ។

ទន្ទឹមនឹងនេះ កម្លាំងពលកម្មជាង ២៤ម៉ឺននាក់ នឹងមានតម្រូវការសម្រាប់តួនាទីគ្រប់គ្រង វិស្វករ និងបច្ចេកទេស (ចំណាត់ថ្នាក់ ISCO ក្រុមទី១ ទី២ និងទី៣)។ មុខតំណែងទាំងនេះនឹងតម្រូវឱ្យមានគុណវុឌ្ឍិកម្រិតខ្ពស់ ដែលជាទូទៅត្រូវមានសញ្ញាបត្របច្ចេកទេសជាន់ខ្ពស់ ឬចាប់ពីកម្រិតនេះឡើងទៅ។

## រូបភាពទី៤៖ ទំហំនៃតម្រូវការការងារតាមអនុវិស័យចម្បងៗ និងតាមកម្រិតជំនាញ នៅឆ្នាំ២០២៦




*ប្រភព៖ ការព្យាករបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយផ្អែកលើអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា ឆ្នាំ២០០០-២០២៣*

*សម្គាល់៖ - ISCO: International Standard Classification of Occupations, CQF: Cambodia Qualifications Framework*

*- ទំនាក់ទំនងរវាងក្រុមមុខរបរធំៗ ISCO-08 និងកម្រិតជំនាញ - ISCO 1 ស្មើនឹងកម្រិតជំនាញ 3 និង 4, ISCO 2 ស្មើនឹងកម្រិតជំនាញ 4, ISCO 3 ស្មើនឹងកម្រិតជំនាញ 3, ISCO 4 5 6 7 និង8 ស្មើនឹងកម្រិតជំនាញ 2, ISCO 9 ស្មើនឹងកម្រិតជំនាញ 1។*

**តម្រូវការកម្រិតគុណវុឌ្ឍិ (CQF )៖**

- អ្នកគ្រប់គ្រង វិស្វករ និងអ្នកមានជំនាញវិជ្ជាជីវៈ៖ បរិញ្ញាបត្រឡើងទៅ
- អ្នកបច្ចេកទេស៖ សញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស/ឯកទេស
- ស្មៀន និងអ្នកធ្វើការផ្នែកសេវាកម្ម និងលក់៖ សញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស/ឯកទេស
- កម្មករជំនាញជាន់ខ្ពស់ និងការីម៉ាស៊ីន និងផ្គុំដំឡើង៖ សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ
- កម្មករជំនាញ អ្នកប្រកបមុខរបរតូចតាច និងអ្នកធ្វើការផ្នែកកសិកម្ម ព្រៃឈើ និងនេសាទ៖ វិញ្ញាបនបត្រវិជ្ជាជីវៈ
- កម្មករមិនមានជំនាញ អ្នកប្រកបមុខរបរតូចតាចៗ និងអ្នកធ្វើការផ្នែកកសិកម្ម ព្រៃឈើ និងនេសាទ៖ ការអប់រំមូលដ្ឋាន

ខាងក្រោមនេះគឺជាការបង្ហាញពីមុខរបរដែលកំពុងមានតម្រូវការច្រើនទៅតាមកម្រិតជំនាញ (ជំនាញឯកទេស គុណវុឌ្ឍិ និងអាជីព) ចំនួនការងារសរុប ស្ថានភាពនិងការប៉ាន់ស្មាន ឱកាសការងារ ការលំបាកក្នុងការជ្រើសរើសកម្មករនិយោជិត ការផ្តល់ឱកាសសម្រាប់អ្នកគ្មានបទពិសោធន៍ កង្វះជំនាញ និងគម្លាតជំនាញតាមអនុវិស័យចម្បងទាំង១៤។




***កំណត់ចំណាំ៖***

- *ព័ត៌មានចំនួនការងារ ចំនួនជ្រើសរើសបុគ្គលិក ការលំបាកក្នុងការជ្រើសរើសកម្មករនិយោជិត ការផ្តល់ឱកាសឱ្យអ្នកគ្មានបទពិសោធន៍ ឱកាសការងារ កង្វះខាតជំនាញ និងបញ្ហាគម្លាតជំនាញ មានប្រភពមកពីរបាយការណ៍អង្កេត និងទិន្នន័យរដ្ឋបាលរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។*
- *ទិន្នន័យប្រាក់ឈ្នួលប្រចាំខែតាមអនុវិស័យជាប្រាក់ឈ្នួលគោលប្រចាំខែដោយមិនរាប់បញ្ចូលអត្ថប្រយោជន៍បន្ថែម ដូចជា៖ ប្រាក់កម្រៃជើងសារ, ប្រាក់សោហ៊ុយធ្វើដំណើរ និងស្នាក់នៅ, ប្រាក់រង្វាន់ធ្វើការទៀងទាត់, ប្រាក់ថ្លៃបាយ, ប្រាក់ឧបត្ថម្ភ និងប្រាក់រង្វាន់អតីតភាពការងារ ជាដើម។*
- *អនុវិស័យដែលមានត្រឹមតែកម្រិតជំនាញមធ្យមឡើងទៅ គឺ អប់រំ, ហិរញ្ញវត្ថុ និងធានារ៉ាប់រង, បច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានវិទ្យា, និង សុខាភិបាល។*

# អនុវិស័យស្នាក់នៅ និងភោជនីយដ្ឋាន

## មុខរបរដែលមានតម្រូវការខ្ពស់ ក្នុងកម្រិតជំនាញទាប



# អនុវិស័យស្នាក់នៅ និងភោជនីយដ្ឋាន

## មុខរបរដែលមានតម្រូវការខ្ពស់ ក្នុងកម្រិតជំនាញមធ្យម



# អនុវិស័យស្នាក់នៅ និងភោជនីយដ្ឋាន

## មុខរបរដែលមានតម្រូវការខ្ពស់ ក្នុងកម្រិតជំនាញខ្ពស់



## មុខរបរដទៃទៀតដែលមានតម្រូវការខ្ពស់ក្នុងអនុវិស័យស្នាក់នៅ និងភោជនីយដ្ឋាន

### ជំនាញកម្រិតទាប (កម្រិត១)

#### អ្នកជួយការងារផ្ទះបាយ
200-220$
បទពិសោធ ១ ឆ្នាំ
ជំនាញ
- បដិសណ្ឋារកិច្ច
- សុខភាព និងសុវត្ថិភាពការងារ

#### អ្នកបោកអ៊ុតដោយដៃ
200-220$
បទពិសោធ ០-២ ឆ្នាំ
ជំនាញ
- សុខភាព និងសុវត្ថិភាពការងារ
- ភាពហ្មត់ចត់ និងស្មោះត្រង់

#### អ្នកនាំសារ និងអ្នកជញ្ជូនអីវ៉ាន់
200-250$
បទពិសោធ ០-២ ឆ្នាំ
ជំនាញ
- បើកបរយានយន្ត
- ការងារលេខាធិការ និងការិយាល័យ

#### អ្នកសម្អាតអនាម័យក្នុងអាគារ
200-250$
បទពិសោធ ០-៣ ឆ្នាំ
ជំនាញ
- សេវាបំរើតាមផ្ទះ
- ភាពហ្មត់ចត់ និងស្មោះត្រង់

### ជំនាញកម្រិតមធ្យម (កម្រិត២)

#### ជាងដំឡើង និងថែទាំជណ្ដើរយន្ត
230-250$
បទពិសោធ ១ ឆ្នាំ
ជំនាញ
- សំណង់
- សុខភាព និងសុវត្ថិភាពការងារ

#### អ្នកទទួលភ្ញៀវក្នុងសណ្ឋាគារ
200-280$
បទពិសោធ ៣ ឆ្នាំ
ជំនាញ
- បដិសណ្ឋារកិច្ច
- ភាសាបរទេស

#### លេខាធិការ (ទូទៅ)
250-300$
បទពិសោធ ២ ឆ្នាំ
ជំនាញ
- កម្មវិធីកំព្យូទ័រ
- ការងារលេខាធិការ និងការិយាល័យ

#### អ្នកប្រឹក្សា និងស្មៀនខាងទេសចរណ៍
200-350$
បទពិសោធ ៣-៥ ឆ្នាំ
ជំនាញ
- ទេសចរណ៍
- ភាសាបរទេស

### ជំនាញកម្រិតខ្ពស់ (កម្រិត៣ និង៤)

#### អ្នកជំនាញផ្នែកផ្សព្វផ្សាយទីផ្សារ
400-450$
បទពិសោធ ៥ ឆ្នាំ
ជំនាញ
- វិស្វកម្មកម្មវិធីកំព្យូទ័រ និងពហុមេឌា
- សារព័ត៌មាន និងរាយការណ៍

#### អ្នកគ្រប់គ្រងធនធានមនុស្ស
450-470$
បទពិសោធ ៥ ឆ្នាំ
ជំនាញ
- និតិសាស្ត្រ
- គ្រប់គ្រង និងរដ្ឋបាល

#### អ្នកបច្ចេកទេសគាំទ្រព័ត៌មានវិទ្យា
330-520$
បទពិសោធ ៥ ឆ្នាំ
ជំនាញ
- អេឡិចត្រូនិក
- គ្រប់គ្រងមូលដ្ឋានទិន្នន័យ និង បណ្ដាញ

#### វិជ្ជាជីវៈទំនាក់ទំនងសាធារណៈ
350-550$
បទពិសោធ ៣-៥ ឆ្នាំ
ជំនាញ
- ភាសាបរទេស
- បដិសណ្ឋារកិច្ច

ចំនួនការងារសរុប



90,380

ក្រុមហ៊ុនកំពុងប្រកាសជ្រើសរើស (%នៃក្រុមហ៊ុនសរុប)



53.61 %

ការប៉ាន់ស្មានចំនួនជ្រើសរើសបុគ្គលិក




2,175

ការលំបាកក្នុងការជ្រើសរើសបុគ្គលិក (%នៃក្រុមហ៊ុនជ្រើសរើសបុគ្គលិក)



34.33 %

ក្រុមហ៊ុនផ្តល់ឱកាសឱ្យអ្នកគ្មានបទពិសោធន៍ (%នៃក្រុមហ៊ុនសរុប)



19.81 %

ឱកាសការងារក្នុងអនុវិស័យនេះ




3.36

រាជធានី/ខេត្ត ទាំង៣ ដែលមានតម្រូវការការងារខ្ពស់




កង្វះខាតជំនាញ (%នៃក្រុមហ៊ុនជ្រើសរើសបុគ្គលិក)



17.69 %

ក្រុមហ៊ុនដែលជួបបញ្ហាគម្លាតជំនាញ (%នៃក្រុមហ៊ុនសរុប)



23.56 %

# អនុវិស័យអប់រំ

## <u>មុខរបរដែលមានតម្រូវការខ្ពស់ ក្នុងកម្រិតជំនាញមធ្យម</u>



# អនុវិស័យអប់រំ

## មុខរបរដែលមានតម្រូវការខ្ពស់ ក្នុងកម្រិតជំនាញមធ្យម





អនុវិស័យអប់រំ
មុខរបរដែលមានតម្រូវការខ្ពស់ ក្នុងកម្រិតជំនាញខ្ពស់
មុខជំនាញ
ISCED-F 2013
សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ ២
វិជ្ជាជីវៈគ្រូបង្រៀនថ្នាក់មត្តេយ្យសិក្សា 0112
សុខុមាលភាព 0920
សង្គមវិទ្យា និងការសិក្សាវប្បធម៌ 0312
អ្នកមើលថែទាំកុមារ
$250-$400
បទពិសោធ
1-3 ឆ្នាំ
ជំនាញទន់
• ភាពអត់ធ្មត់
• ការចេះយល់ចិត្ត
សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ ៣
វិជ្ជាជីវៈគ្រូបង្រៀនថ្នាក់មត្តេយ្យសិក្សា 0112
សុខុមាលភាព 0920
សង្គមវិទ្យា និងការសិក្សាវប្បធម៌ 0312
គ្រូបង្រៀនថ្នាក់មត្តេយ្យសិក្សា
$350-$500
បទពិសោធ
3-5ឆ្នាំ
ជំនាញទន់
• ការទំនាក់ទំនង
• ការចេះសម្របខ្លួន
សញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស/ឯកទេស ឡើងទៅ
វិជ្ជាជីវៈគ្រូបង្រៀនថ្នាក់មត្តេយ្យសិក្សា 0112
សុខុមាលភាព 0920
សង្គមវិទ្យា និងការសិក្សាវប្បធម៌ 0312
គ្រូបង្រៀនអប់រំកម្រិតថ្នាក់មត្តេយ្យ
$400-$550
បទពិសោធ
5-7 ឆ្នាំ
ជំនាញទន់
• ការរចនាសេចក្តីណែនាំ
• ការបង្ហាត់បង្ហាញ
បរិញ្ញាបត្រឡើងទៅ
ពាណិជ្ជកម្ម និងរដ្ឋបាល 0410
វិទ្យាសាស្ត្រអប់រំ 0111
ការគ្រប់គ្រង និងរដ្ឋបាល 0413
អ្នកសម្របសម្រួលផ្នែកកុមារតូច
$800-$1200
បទពិសោធ
7-10 ឆ្នាំ
ជំនាញទន់
• ភាពជាអ្នកដឹកនាំ
• ការអភិវឌ្ឍកម្មវិធីសិក្សា
នាយកសាលាមត្តេយ្យ
$1200-$2000
បទពិសោធ
10 ឆ្នាំឡើង
ជំនាញទន់
• ការគ្រប់គ្រងជាយុទ្ធសាស្ត្រ
• ទំនាក់ទំនងសាធារណៈ

## មុខរបរដទៃទៀតដែលមានតម្រូវការខ្ពស់ក្នុងអនុវិស័យអប់រំ

### ជំនាញកម្រិតទាប (កម្រិត១)

**អ្នកជួយការងារផ្ទះបាយ**
200-220$
បទពិសោធ ១ ឆ្នាំ
ជំនាញ
- បដិសណ្ឋារកិច្ច
- សុខភាព និងសុវត្ថិភាពការងារ

**អ្នកសម្អាតយានយន្ត**
200-220$
បទពិសោធ ០-១ ឆ្នាំ
ជំនាញ
- បើកបរយានយន្ត
- ភាពហ្មត់ចត់ និងស្មោះត្រង់

**អ្នកនាំសារ និងអ្នកជញ្ជូនអីវ៉ាន់**
200-250$
បទពិសោធ ០-២ ឆ្នាំ
ជំនាញ
- បើកបរយានយន្ត
- ការងារលេខាធិការ និងការិយាល័យ

**អ្នកសម្អាតអនាម័យក្នុងអាគារ**
200-250$
បទពិសោធ ០-៣ ឆ្នាំ
ជំនាញ
- សេវាបំរើតាមផ្ទះ
- ភាពហ្មត់ចត់ និងស្មោះត្រង់

### ជំនាញកម្រិតមធ្យម (កម្រិត២)

**អ្នកថែទាំអាគារ**
230-250$
បទពិសោធ ១ ឆ្នាំ
ជំនាញ
- សំណង់
- សុខភាព និងសុវត្ថិភាពការងារ

**អ្នកទទួលភ្ញៀវ (ទូទៅ)**
200-280$
បទពិសោធ ៣ ឆ្នាំ
ជំនាញ
- កម្មវិធីកំព្យូទ័រ
- ភាសាបរទេស

**លេខាធិការ (ទូទៅ)**
250-300$
បទពិសោធ ២ ឆ្នាំ
ជំនាញ
- កម្មវិធីកំព្យូទ័រ
- ការងារលេខាធិការ និងការិយាល័យ

**ស្មៀនផ្នែកគណនេយ្យ និងបញ្ជី**
300-400$
បទពិសោធ ១-៣ ឆ្នាំ
ជំនាញ
- គណនេយ្យ និងពន្ធដារ
- ហិរញ្ញវត្ថុ និងធនាគារ

### ជំនាញកម្រិតខ្ពស់ (កម្រិត៣ និង៤)

**អ្នកជំនាញផ្នែកផ្សព្វផ្សាយទីផ្សារ**
350-400$
បទពិសោធ ៣ ឆ្នាំ
ជំនាញ
- គ្រប់គ្រងពាណិជ្ជកម្ម
- វិស្វកម្មកម្មវិធីកំព្យូទ័រ និងពហុមេឌា

**អ្នកគ្រប់គ្រងធនធានមនុស្ស**
600-700$
បទពិសោធ ៥ ឆ្នាំ
ជំនាញ
- សេដ្ឋកិច្ច និងគ្រប់គ្រង
- គ្រប់គ្រង និងរដ្ឋបាល

**អ្នកបច្ចេកទេសគាំទ្រព័ត៌មានវិទ្យា**
400-450$
បទពិសោធ ៣ ឆ្នាំ
ជំនាញ
- អេឡិចត្រូនិក
- សេវាបណ្តាញ និងរដ្ឋបាលប្រព័ន្ធ

**គ្រូបង្រៀនកម្រិតមធ្យមសិក្សា**
350-550$
បទពិសោធ ៣-៥ ឆ្នាំ
ជំនាញ
- វិទ្យាសាស្ត្រអប់រំ
- បំនិន និងការអភិវឌ្ឍបុគ្គល

ចំនួនការងារសរុប
43,133

ក្រុមហ៊ុនកំពុងប្រកាសជ្រើសរើស (%នៃក្រុមហ៊ុនសរុប)
70.34 %

ការប៉ាន់ស្មានចំនួនជ្រើសរើសបុគ្គលិក
1,323

ការលំបាកក្នុងការជ្រើសរើសបុគ្គលិក (%នៃក្រុមហ៊ុនជ្រើសរើសបុគ្គលិក)
22.72 %

ក្រុមហ៊ុនផ្តល់ឱកាសឱ្យអ្នកគ្មានបទពិសោធន៍ (%នៃក្រុមហ៊ុនសរុប)
40.74 %

ឱកាសការងារក្នុងអនុវិស័យនេះ



3.04

កង្វះខាតជំនាញ (%នៃក្រុមហ៊ុនជ្រើសរើសបុគ្គលិក)
16.69 %

ក្រុមហ៊ុនដែលជួបបញ្ហាគម្លាតជំនាញ (%នៃក្រុមហ៊ុនសរុប)
29.93 %

រាជធានី/ខេត្ត ទាំង៣ ដែលមានតម្រូវការការងារខ្ពស់





អនុវិស័យហិរញ្ញវត្ថុ និងធានារ៉ាប់រង
មុខរបរដែលមានតម្រូវការខ្ពស់ ក្នុងកម្រិតជំនាញមធ្យម
មុខជំនាញ
ISCED-F 2013
សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ ២
ហិរញ្ញវត្ថុ ធនាគារ និងធានារ៉ាប់រង 0412
គណនេយ្យ និងពន្ធដារ 0411
ពាណិជ្ជកម្ម និងរដ្ឋបាល 0410
ស្មៀនការិយាល័យទូទៅ
$250-$400
បទពិសោធ
1-2 ឆ្នាំ
ជំនាញទន់
• ការយកចិត្តទុកដាក់លើព័ត៌មានលម្អិត
• ការគ្រប់គ្រងពេលវេលា
សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ ៣
ហិរញ្ញវត្ថុ ធនាគារ និងធានារ៉ាប់រង 0412
គណនេយ្យ និងពន្ធដារ 0411
ពាណិជ្ជកម្ម និងរដ្ឋបាល 0410
បេឡាករធនាគារ
$350-$500
បទពិសោធ
2-4 ឆ្នាំ
ជំនាញទន់
• ការអនុវត្តដំណើរការ
• ការធ្វើរបាយការណ៍មូលដ្ឋាន
សញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស/ឯកទេសឡើងទៅ
ហិរញ្ញវត្ថុ ធនាគារ និងធានារ៉ាប់រង 0412
សេដ្ឋកិច្ច 0431
ការគ្រប់គ្រង និងរដ្ឋបាល 0413
មន្ត្រីឥណទាន
$400-$750
បទពិសោធ
4-6 ឆ្នាំ
ជំនាញទន់
• ការវិភាគហិរញ្ញវត្ថុ
• ការអនុលោមតាមច្បាប់
បរិញ្ញាបត្រឡើងទៅ
ហិរញ្ញវត្ថុ ធនាគារ និងធានារ៉ាប់រង 0412
សេដ្ឋកិច្ច 0431
ការគ្រប់គ្រង និងរដ្ឋបាល 0413
ប្រធានផ្នែកគ្រប់គ្រងសាខាស្ថាប័នហិរញ្ញវត្ថុ
$1000-$1800
បទពិសោធ
6-9 ឆ្នាំ
ជំនាញទន់
• ភាពជាអ្នកដឹកនាំ
• ការធ្វើផែនការយុទ្ធសាស្ត្រ
ប្រធានផ្នែកគ្រប់គ្រងផែនការ និងយុទ្ធសាស្ត្រ
$1800-$2800
បទពិសោធ
9-12 ឆ្នាំ
ជំនាញទន់
• ការគ្រប់គ្រងភាគីពាក់ព័ន្ធ
• ការចរចា
នាយកគ្រប់គ្រងធនាគារប្រចាំតំបន់
$2800 ឡើង
បទពិសោធ
12 ឆ្នាំឡើង
ជំនាញទន់
• ចក្ខុវិស័យសហគ្រាស
• ទំនាក់ទំនងក្រុមប្រឹក្សាភិបាល

# អនុវិស័យហិរញ្ញវត្ថុ និងធានារ៉ាប់រង

## មុខរបរដែលមានតម្រូវការខ្ពស់ ក្នុងកម្រិតជំនាញមធ្យម

**មុខជំនាញ** ISCED-F 2013



# អនុវិស័យហិរញ្ញវត្ថុ និងធានារ៉ាប់រង

## មុខរបរដែលមានតម្រូវការខ្ពស់ ក្នុងកម្រិតជំនាញខ្ពស់



## មុខរបរដទៃទៀតដែលមានតម្រូវការខ្ពស់ក្នុងអនុវិស័យហិរញ្ញវត្ថុ និងធានារ៉ាប់រង

### ជំនាញកម្រិតទាប (កម្រិត១)

**អ្នកនាំសារ និងអ្នកដឹកជញ្ជូនអីវ៉ាន់**
- 178-230$
- បទពិសោធ ០-២ ឆ្នាំ
- ជំនាញ
  - បើកបរយានយន្ត
  - ការងារលេខាធិការ និងការិយាល័យ

**អ្នកសម្អាតអនាម័យក្នុងអគារ**
- 180-200$
- បទពិសោធ ០-៣ ឆ្នាំ
- ជំនាញ
  - សេវាបំរើតាមផ្ទះ
  - ភាពហ្មត់ចត់ និងស្មោះត្រង់

**អ្នកជួយការងារផ្ទះបាយ**
- 200-220$
- បទពិសោធ ១ ឆ្នាំ
- ជំនាញ
  - បដិសណ្ឋារកិច្ច
  - សុខភាព និងសុវត្ថិភាពការងារ

**អ្នកបើកបររថយន្ត**
- 270-280$
- បទពិសោធ ៣ ឆ្នាំ
- ជំនាញ
  - បើកបរយានយន្ត
  - សុខភាព និងសុវត្ថិភាពការងារ

### ជំនាញកម្រិតមធ្យម (កម្រិត២)

**អ្នកថែទាំអាគារ**
- 230-250$
- បទពិសោធ ១ ឆ្នាំ
- ជំនាញ
  - សំណង់
  - សុខភាព និងសុវត្ថិភាពការងារ

**ស្មៀនវាយបញ្ចូលទិន្នន័យ**
- 250-280$
- បទពិសោធ ៣ ឆ្នាំ
- ជំនាញ
  - កម្មវិធីកំព្យូទ័រ
  - ការងារលេខាធិការ និងការិយាល័យ

**លេខាធិការ (ទូទៅ)**
- 250-300$
- បទពិសោធ ២ ឆ្នាំ
- ជំនាញ
  - កម្មវិធីកំព្យូទ័រ
  - ការងារលេខាធិការ និងការិយាល័យ

**អ្នកទំនាក់ទំនងផ្នែកលក់តាមទូរស័ព្ទ**
- 300-320$
- បទពិសោធ ០-២ ឆ្នាំ
- ជំនាញ
  - ទីផ្សារ
  - គ្រប់គ្រងពាណិជ្ជកម្ម

### ជំនាញកម្រិតខ្ពស់ (កម្រិត៣ និង៤)

**អ្នកជំនាញផ្នែកផ្សព្វផ្សាយទីផ្សារ**
- 350-500$
- បទពិសោធ ៣ ឆ្នាំ
- ជំនាញ
  - វិស្វកម្មកម្មវិធីកំព្យូទ័រ និងពហុមេឌា
  - សុខភាព និងសុវត្ថិភាពការងារ

**អ្នកគ្រប់គ្រងធនធានមនុស្ស**
- 450-470$
- បទពិសោធ ៥ ឆ្នាំ
- ជំនាញ
  - នីតិសាស្ត្រ
  - គ្រប់គ្រង និងរដ្ឋបាល

**អ្នកបច្ចេកទេសគាំទ្រព័ត៌មានវិទ្យា**
- 330-520$
- បទពិសោធ 0-២ឆ្នាំ
- ជំនាញ
  - អេឡិចត្រូនិក
  - គ្រប់គ្រងមូលដ្ឋានទិន្នន័យ និងបណ្តាញ

**អ្នកគ្រប់គ្រងផ្នែកសេវាកម្មវិជ្ជាជីវៈ**
- 800-1100$
- បទពិសោធ ៥ ឆ្នាំ
- ជំនាញ
  - គ្រប់គ្រងពាណិជ្ជកម្ម
  - ការគ្រប់គ្រង និងរដ្ឋបាល

ចំនួនការងារសរុប: 178,626

ក្រុមហ៊ុនកំពុងប្រកាសជ្រើសរើស (%នៃក្រុមហ៊ុនសរុប): 69.99 %

ការប៉ាន់ស្មានចំនួនជ្រើសរើសបុគ្គលិក: 4,769

ការលំបាកក្នុងការជ្រើសរើសបុគ្គលិក (%នៃក្រុមហ៊ុនជ្រើសរើសបុគ្គលិក): 26.70 %

ក្រុមហ៊ុនផ្តល់ឱកាសឱ្យអ្នកគ្មានបទពិសោធន៍ (%នៃក្រុមហ៊ុនសរុប): 20.36 %

ឱកាសការងារក្នុងអនុវិស័យនេះ: 3.09




កង្វះខាតជំនាញ (%នៃក្រុមហ៊ុនជ្រើសរើសបុគ្គលិក): 12.59 %

ក្រុមហ៊ុនដែលជួបបញ្ហាគម្លាតជំនាញ (%នៃក្រុមហ៊ុនសរុប): 23.14 %

រាជធានី/ខេត្ត ទាំង៣ ដែលមានតម្រូវការការងារខ្ពស់




អនុវិស័យសេវាសុខាភិបាល
មុខរបរដែលមានតម្រូវការខ្ពស់ ក្នុងកម្រិតជំនាញមធ្យម
មុខជំនាញ
ISCED-F 2013
សញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស/ឯកទេស
ការគ្រប់គ្រង និងរដ្ឋបាល 0413
សុខុមាលភាព 0920
សុខភាព និងសុវត្ថិភាពការងារ 1022
គិលានុបដ្ឋាក និងឆ្មប 0913
បច្ចេកវិទ្យាវិភាគរោគ និងការព្យាបាលវេជ្ជសាស្ត្រ 0914
ការគ្រប់គ្រង និងរដ្ឋបាល 0413
ជំនួយការពេទ្យ
$250-$400
បទពិសោធ 1-3 ឆ្នាំ
ជំនាញទន់
• ការសម្របសម្រួលរហ័ស
• ចេះយល់ចិត្ត
ជំនួយការគិលានុបដ្ឋាក
$400-$600
បទពិសោធ 3-5 ឆ្នាំ
ជំនាញទន់
• ការគិតស៊ីជម្រៅ
• ការគ្រប់គ្រងសម្ពាធ
គិលានុបដ្ឋាក
$600-$900
បទពិសោធ 5-7 ឆ្នាំ
ជំនាញទន់
• ការយកចិត្តទុកដាក់លើព័ត៌មានលម្អិត
• ការទំនាក់ទំនងជាមួយអ្នកជំងឺ
បរិញ្ញាបត្រឡើងទៅ
វេជ្ជសាស្ត្រ 0912
គិលានុបដ្ឋាក និងឆ្មប 0913
បច្ចេកវិទ្យាវិភាគរោគ និងការព្យាបាលវេជ្ជសាស្ត្រ 0914
ការគ្រប់គ្រង និងរដ្ឋបាល 0413
ប្រធានផ្នែកគិលានុបដ្ឋាក
$1000ឡើង
បទពិសោធ 7-10 ឆ្នាំ
ជំនាញទន់
• ភាពជាអ្នកដឹកនាំ
• ការវែកញែកវិភាគ
នាយកគ្រប់គ្រងផ្នែកគិលានុបដ្ឋាក
$1500 ឡើង
បទពិសោធ 10 ឆ្នាំឡើង
ជំនាញទន់
• ភាពជាក់លាក់កម្រិតខ្ពស់
• ការពិគ្រោះយោបល់អ្នកជំនាញ
នាយកគ្លីនិក
$3000 ឡើង
បទពិសោធ 15 ឆ្នាំឡើង
ជំនាញទន់
• ការគិតបែបយុទ្ធសាស្ត្រកម្រិតសហគ្រាស
• ការទំនាក់ទំនងក្រុមប្រឹក្សាភិបាល

# អនុវិស័យសេវាសុខាភិបាល

## មុខរបរដែលមានតម្រូវការខ្ពស់ ក្នុងកម្រិតជំនាញមធ្យម

| មុខជំនាញ | ISCED-F 2013 |
|---|---|

### សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ ២

| | |
|---|---|
| សេវាដឹកជញ្ជូន | 1041 |
| គិលានុបដ្ឋាក និងឆ្មប | 0913 |
| សុខភាព និងសុវត្ថិភាពការងារ | 1022 |

**អ្នកបើកបររថយន្តសង្គ្រោះបន្ទាន់**
- $350-$550
- បទពិសោធន៍ 1-3 ឆ្នាំ
- ជំនាញទន់
  - ការសម្របសម្រួលរហ័ស
  - ចេះយល់ចិត្ត

### សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ ៣

| | |
|---|---|
| វេជ្ជសាស្ត្រ | 0912 |
| បច្ចេកវិទ្យាវិភាគរោគ និងការព្យាបាលវេជ្ជសាស្ត្រ | 0914 |
| ការគ្រប់គ្រង និងរដ្ឋបាល | 0413 |

**ស្មៀនការិយាល័យទូទៅ**
- $400-$600
- បទពិសោធ 3-5 ឆ្នាំ
- ជំនាញទន់
  - ការគិតស៊ីជម្រៅ
  - ការគ្រប់គ្រងសម្ពាធ

### សញ្ញាបត្រជាន់ខ្ពស់ បច្ចេកទេស/ឯកទេស

| | |
|---|---|
| ពាណិជ្ជកម្ម និងរដ្ឋបាល | 0913 |
| សុខាភិបាល | 0910 |
| បច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានវិទ្យា (ICT) | 0610 |

**អ្នកគ្រប់គ្រងសេវាកម្មរដ្ឋបាល**
- $500-$800
- បទពិសោធ 5-7 ឆ្នាំ
- ជំនាញទន់
  - ការយកចិត្តទុកដាក់លើព័ត៌មានលម្អិត
  - ការទំនាក់ទំនងជាមួយអ្នកជំងឺ

### បរិញ្ញាបត្រឡើងទៅ

| | |
|---|---|
| សុខាភិបាល | 0910 |
| បច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានវិទ្យា (ICT) | 0610 |
| ការគ្រប់គ្រង និងរដ្ឋបាល | 0413 |

**អ្នកគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យាសុខាភិបាល**
- $1000 ឡើង
- បទពិសោធ 7-10 ឆ្នាំ
- ជំនាញទន់
  - ការវែកញែកវិភាគ
  - ភាពជាអ្នកដឹកនាំ

| | |
|---|---|
| សុខាភិបាល | 0910 |
| ពាណិជ្ជកម្ម និងរដ្ឋបាល | 0410 |
| ការគ្រប់គ្រង និងរដ្ឋបាល | 0413 |

**នាយកប្រតិបត្តិការមន្ទីរពេទ្យ**
- $2000 ឡើង
- បទពិសោធ 10 ឆ្នាំឡើង
- ជំនាញទន់
  - ភាពជាក់លាក់កម្រិតខ្ពស់
  - ការពិគ្រោះយោបល់អ្នកជំនាញ

**នាយកមន្ទីរពេទ្យ**
- $3000 ឡើង
- បទពិសោធ 15 ឆ្នាំឡើង
- ជំនាញទន់
  - អភិបាលកិច្ចជាយុទ្ធសាស្ត្រ
  - ការគ្រប់គ្រងហានិភ័យជាប្រព័ន្ធ

# អនុវិស័យសេវាសុខាភិបាល

## មុខរបរដែលមានតម្រូវការខ្ពស់ ក្នុងកម្រិតជំនាញខ្ពស់



## មុខរបរដទៃទៀតដែលមានតម្រូវការខ្ពស់ក្នុងអនុវិស័យសេវាសុខាភិបាល

### ជំនាញកម្រិតទាប (កម្រិត១)

**អ្នកជួយការងារផ្ទះបាយ**
- 200-220$
- បទពិសោធ ១ ឆ្នាំ
- ជំនាញ
  - បដិសណ្ឋារកិច្ច
  - សុខភាព និងសុវត្ថិភាពការងារ

**អ្នកបោកអ៊ុតដោយដៃ**
- 200-220$
- បទពិសោធ ០-២ ឆ្នាំ
- ជំនាញ
  - ភាពហ្មត់ចត់ និងស្មោះត្រង់
  - សុខភាព និងសុវត្ថិភាពការងារ

**អ្នកនាំសារ និងអ្នកជញ្ជូនអីវ៉ាន់**
- 200-220$
- បទពិសោធ ០-២ ឆ្នាំ
- ជំនាញ
  - បើកបរយានយន្ត
  - ការងារលេខាធិការ និងការិយាល័យ

**អ្នកសម្អាតអនាម័យក្នុងអាគារ**
- 200-220$
- បទពិសោធ ០-៣ ឆ្នាំ
- ជំនាញ
  - សេវាបំរើតាមផ្ទះ
  - ភាពហ្មត់ចត់ និងស្មោះត្រង់

### ជំនាញកម្រិតមធ្យម (កម្រិត២)

**អ្នកទទួលភ្ញៀវ (ទូទៅ)**
- 200-280$
- បទពិសោធ ៣ ឆ្នាំ
- ជំនាញ
  - បដិសណ្ឋារកិច្ច
  - ភាសាបរទេស

**ស្មៀនផ្នែកគណនេយ្យ និងបញ្ជី**
- 300-400$
- បទពិសោធ ៣-៥ ឆ្នាំ
- ជំនាញ
  - គណនេយ្យ និងពន្ធដារ
  - ហិរញ្ញវត្ថុ និងធនាគារ

**លេខាធិការ (ទូទៅ)**
- 400-500$
- បទពិសោធ ២ ឆ្នាំ
- ជំនាញ
  - កម្មវិធីកំព្យូទ័រ
  - ការងារលេខាធិការ និងការិយាល័យ

**អ្នកថែទាំអាគារ**
- 450-500$
- បទពិសោធ ៣-៥ ឆ្នាំ
- ជំនាញ
  - សំណង់
  - សុខភាព និងសុវត្ថិភាពការងារ

### ជំនាញកម្រិតខ្ពស់ (កម្រិត៣ និង៤)

**សហការីវិជ្ជាជីវៈជំនាញផ្នែកគិលានុបដ្ឋាក**
- 350-450$
- បទពិសោធ ៣-៥ ឆ្នាំ
- ជំនាញ
  - គិលានុបដ្ឋាក
  - ចំណេះដឹងវេជ្ជសាស្ត្រ

**ជំនួយការពេទ្យ**
- 400-600$
- បទពិសោធ ៣-៥ ឆ្នាំ
- ជំនាញ
  - ការថែទាំ
  - ចំណេះដឹងវេជ្ជសាស្ត្រ

**អ្នកគ្រប់គ្រងសេវាសុខាភិបាល**
- 1000$ ឡើង
- បទពិសោធ ៥-៨ ឆ្នាំ
- ជំនាញ
  - ចំណេះដឹងវេជ្ជសាស្ត្រ
  - សេដ្ឋកិច្ច និងគ្រប់គ្រង

**អ្នកគ្រប់គ្រងធនធានមនុស្ស**
- 1000$ ឡើង
- បទពិសោធ ១០ ឆ្នាំ
- ជំនាញ
  - ការគ្រប់គ្រង និងរដ្ឋបាល
  - ចំណេះដឹងវេជ្ជសាស្ត្រ

ចំនួនការងារសរុប: 9,903

ក្រុមហ៊ុនកំពុងប្រកាសជ្រើសរើស (%នៃក្រុមហ៊ុនសរុប): 40.20 %

ការប៉ាន់ស្មានចំនួនជ្រើសរើសបុគ្គលិក: 407

ការលំបាកក្នុងការជ្រើសរើសបុគ្គលិក (%នៃក្រុមហ៊ុនជ្រើសរើសបុគ្គលិក): 27.33 %

ក្រុមហ៊ុនផ្តល់ឱកាសឱ្យអ្នកគ្មានបទពិសោធន៍ (%នៃក្រុមហ៊ុនសរុប): 19.75 %

ឱកាសការងារក្នុងអនុវិស័យនេះ: 3.27




កង្វះខាតជំនាញ (%នៃក្រុមហ៊ុនជ្រើសរើសបុគ្គលិក): 22.19 %

ក្រុមហ៊ុនដែលជួបបញ្ហាគម្លាតជំនាញ (%នៃក្រុមហ៊ុនសរុប): 12.08 %

រាជធានី/ខេត្ត ទាំង២ ដែលមានតម្រូវការការងារខ្ពស់



# អនុវិស័យបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានវិទ្យា (ICT)

## មុខរបរដែលមានតម្រូវការខ្ពស់ ក្នុងកម្រិតជំនាញមធ្យម



# អនុវិស័យបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានវិទ្យា (ICT)

## មុខរបរដែលមានតម្រូវការខ្ពស់ ក្នុងកម្រិតជំនាញមធ្យម

| មុខជំនាញ | ISCED-F 2013 |
|---|---|

### សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ ២

| មុខជំនាញ | ISCED-F 2013 |
|---|---|
| ពាណិជ្ជកម្ម និងរដ្ឋបាល | 0410 |
| ទីផ្សារ និងការផ្សព្វផ្សាយពាណិជ្ជកម្ម | 0414 |
| ការប្រើប្រាស់កុំព្យូទ័រ | 0611 |

**ជំនួយការទីផ្សារឌីជីថល**

- $250-$400
- បទពិសោធ 1-2 ឆ្នាំ

ជំនាញទន់
- ភាពរួសរាយ
- ការទំនាក់ទំនង

### សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ ៣

| មុខជំនាញ | ISCED-F 2013 |
|---|---|
| បច្ចេកទេសសោតទស្សន៍ និង ការផលិតប្រព័ន្ធផ្សព្វផ្សាយ | 0211 |
| ពាណិជ្ជកម្ម និងរដ្ឋបាល | 0410 |
| ទីផ្សារ និងការផ្សព្វផ្សាយពាណិជ្ជកម្ម | 0414 |

**អ្នកសម្របសម្រួលខ្លឹមសារបណ្តាញសង្គម**

- $300-$500
- បទពិសោធ 2-4 ឆ្នាំ

ជំនាញទន់
- ការបញ្ចុះបញ្ចូល
- ការច្នៃប្រឌិតលើភាសាទំនាក់ទំនង

### សញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស/ឯកទេស

| មុខជំនាញ | ISCED-F 2013 |
|---|---|
| ទីផ្សារ និងការផ្សព្វផ្សាយពាណិជ្ជកម្ម | 0414 |
| បច្ចេកទេសសោតទស្សន៍ និងការផលិតប្រព័ន្ធផ្សព្វផ្សាយ | 0211 |
| ការរចនា និងការគ្រប់គ្រងមូលដ្ឋានទិន្នន័យ និងបណ្តាញ | 0612 |

**អ្នករចនាបោះពុម្ពផ្សាយ**

- $500-$700
- បទពិសោធ 4-6 ឆ្នាំ

ជំនាញទន់
- ភាពច្នៃប្រឌិតខាងគំនូរ
- ការគិតជាយុទ្ធសាស្ត្រ

### បរិញ្ញាបត្រឡើងទៅ

| មុខជំនាញ | ISCED-F 2013 |
|---|---|
| បច្ចេកវិទ្យា គមនាគមន៍ និង ព័ត៌មានវិទ្យា (ICT) | 0610 |
| ការរចនា និងការគ្រប់គ្រងមូលដ្ឋានទិន្នន័យ និងបណ្តាញ | 0612 |
| ការគ្រប់គ្រង និងរដ្ឋបាល | 0413 |

**នាយកផ្នែកទីផ្សារ**

- $1200 ឡើង
- បទពិសោធ 6 ឆ្នាំឡើង

ជំនាញទន់
- ភាពជាអ្នកដឹកនាំ
- ការបញ្ចុះបញ្ចូល

| មុខជំនាញ | ISCED-F 2013 |
|---|---|
| បច្ចេកទេសសោតទស្សន៍ និងការផលិតប្រព័ន្ធផ្សព្វផ្សាយ | 0211 |
| ការរចនាម៉ូដ ផ្នែកខាងក្នុង និងឧស្សាហកម្ម | 0212 |
| ទីផ្សារ និងការផ្សព្វផ្សាយពាណិជ្ជកម្ម | 0414 |
| ការគ្រប់គ្រង និងរដ្ឋបាល | 0413 |

**នាយកគ្រប់គ្រងផ្នែកផ្សព្វផ្សាយពាណិជ្ជកម្ម**

- $1800 ឡើង
- បទពិសោធ 9 ឆ្នាំឡើង

ជំនាញទន់
- ភាពជាដៃគូយុទ្ធសាស្ត្រ
- ការធ្វើបទបង្ហាញប្រតិបត្តិ

**នាយកប្រតិបត្តិ**

- $2800 ឡើង
- បទពិសោធ 12 ឆ្នាំឡើង

ជំនាញទន់
- ចក្ខុវិស័យម៉ាកយីហោ
- យុទ្ធសាស្ត្រសហគ្រាស

# អនុវិស័យបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានវិទ្យា ( ICT )

## មុខរបរដែលមានតម្រូវការខ្ពស់ ក្នុងកម្រិតជំនាញខ្ពស់

| មុខជំនាញ | ISCED-F 2013 |
|---|---|

### សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ ២

| មុខជំនាញ | ISCED-F 2013 |
|---|---|
| ពាណិជ្ជកម្ម និងរដ្ឋបាល | 0410 |
| ការប្រើប្រាស់កុំព្យូទ័រ | 0611 |
| ការរចនា និងការគ្រប់គ្រងមូលដ្ឋានទិន្នន័យ និងបណ្ដាញ | 0612 |

**ជំនួយការផ្នែកគាំទ្រ IT**

- $300-$400
- បទពិសោធ 1-2 ឆ្នាំ

ជំនាញទន់

- ភាពរួសរាយ
- ការទំនាក់ទំនង

### សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ ៣

| មុខជំនាញ | ISCED-F 2013 |
|---|---|
| បច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានវិទ្យា (ICT) | 0610 |
| ការរចនា និងការគ្រប់គ្រងមូលដ្ឋានទិន្នន័យ និងបណ្ដាញ | 0612 |
| អេឡិចត្រូនិក និងស្វ័យប្រវត្តិកម្ម | 0714 |

**អ្នកដំឡើង និងផ្តល់សេវា IT**

- $350-$500
- បទពិសោធ 2-4 ឆ្នាំ

ជំនាញទន់

- ភាពអត់ធ្មត់
- ការយកចិត្តទុកដាក់លើព័ត៌មានលម្អិត

### សញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស/ឯកទេស

| មុខជំនាញ | ISCED-F 2013 |
|---|---|
| បច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានវិទ្យា (ICT) | 0610 |
| ការរចនា និងការគ្រប់គ្រងមូលដ្ឋានទិន្នន័យ និងបណ្ដាញ | 0612 |
| អេឡិចត្រូនិក និងស្វ័យប្រវត្តិកម្ម | 0714 |

**អ្នកគ្រប់គ្រងបណ្ដាញ និងប្រព័ន្ធ**

- $600-$800
- បទពិសោធ 4-6 ឆ្នាំ

ជំនាញទន់

- ការគ្រប់គ្រងក្រុម
- ការធ្វើឱ្យប្រសើរឡើងដំណើរការ

### បរិញ្ញាបត្រឡើងទៅ

| មុខជំនាញ | ISCED-F 2013 |
|---|---|
| បច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានវិទ្យា (ICT) | 0610 |
| ការរចនា និងការគ្រប់គ្រងមូលដ្ឋានទិន្នន័យ និងបណ្ដាញ | 0612 |
| អេឡិចត្រូនិក និងស្វ័យប្រវត្តិកម្ម | 0714 |

**អ្នកជំនាញឯកទេសសុវត្ថិភាពព័ត៌មានវិទ្យា**

- $1000 ឡើង
- បទពិសោធ 6 ឆ្នាំឡើង

ជំនាញទន់

- ការធ្វើឱ្យប្រសើរឡើងដំណើរការ
- ការធ្វើផែនការ

| មុខជំនាញ | ISCED-F 2013 |
|---|---|
| បច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានវិទ្យា (ICT) | 0610 |
| ការរចនា និងការគ្រប់គ្រងមូលដ្ឋានទិន្នន័យ និងបណ្ដាញ | 0612 |
| ការគ្រប់គ្រង និងរដ្ឋបាល | 0413 |

**នាយកប្រតិបត្តិការព័ត៌មានបច្ចេកវិទ្យា**

- $1500 ឡើង
- បទពិសោធ 10 ឆ្នាំឡើង

ជំនាញទន់

- ភាពជាអ្នកដឹកនាំ
- យុទ្ធសាស្ត្រសាជីវកម្ម

## មុខរបរដទៃទៀតដែលមានតម្រូវការខ្ពស់ក្នុងអនុវិស័យបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានវិទ្យា (ICT)

### ជំនាញកម្រិតទាប (កម្រិត១)

**អ្នកនាំសារ និងអ្នកដឹកជញ្ជូនអីវ៉ាន់**
200-250$
បទពិសោធ 0-២ ឆ្នាំ
ជំនាញ
- បើកបរយានយន្ត
- ការងារលេខាធិការ និងការិយាល័យ

**អ្នកសម្អាតអនាម័យក្នុងអគារ**
200-250$
បទពិសោធ 0-៣ ឆ្នាំ
ជំនាញ
- សេវាបំរើតាមផ្ទះ
- ភាពហ្មត់ចត់ និងស្មោះត្រង់

**អ្នកផ្គុំដំឡើងឧបករណ៍អគ្គិសនី**
220-280$
បទពិសោធ 0-២ ឆ្នាំ
ជំនាញ
- ភាពហ្មត់ចត់ និងស្មោះត្រង់
- សុខភាព និងសុវត្ថិភាពការងារ

**អ្នករៀបអីវ៉ាន់ដាក់លើធ្នើ**
240-290$
បទពិសោធ 0-២ ឆ្នាំ
ជំនាញ
- ការគ្រប់គ្រងស្តុក និងឃ្លាំង
- សុខភាព និងសុវត្ថិភាពការងារ

### ជំនាញកម្រិតមធ្យម (កម្រិត២)

**អ្នកថែទាំអាគារ**
230-250$
បទពិសោធ ១ ឆ្នាំ
ជំនាញ
- សំណង់
- សុខភាព និងសុវត្ថិភាពការងារ

**ស្មៀនវាយបញ្ចូលទិន្នន័យ**
250-280$
បទពិសោធ ៣ ឆ្នាំ
ជំនាញ
- កម្មវិធីកំព្យូទ័រ
- ការងារលេខាធិការ និងការិយាល័យ

**លេខាធិការ (ទូទៅ)**
250-300$
បទពិសោធ ២ ឆ្នាំ
ជំនាញ
- កម្មវិធីកំព្យូទ័រ
- ការងារលេខាធិការ និងការិយាល័យ

**អ្នកទំនាក់ទំនងផ្នែកលក់តាមទូរស័ព្ទ**
300-320$
បទពិសោធ 0-៣ ឆ្នាំ
ជំនាញ
- ទីផ្សារ
- គ្រប់គ្រងពាណិជ្ជកម្ម

### ជំនាញកម្រិតខ្ពស់ (កម្រិត៣ និង៤)

**អ្នកជំនាញផ្នែកផ្សព្វផ្សាយទីផ្សារ**
350-500$
បទពិសោធ ៣-៥ ឆ្នាំ
ជំនាញ
- វិស្វកម្មកម្មវិធីកំព្យូទ័រ និងពហុមេឌា
- សារព័ត៌មាន និងរាយការណ៍

**នាយកផ្នែកទីផ្សារ**
500-600$
បទពិសោធ ២-៤ ឆ្នាំ
ជំនាញ
- ទីផ្សារ
- គ្រប់គ្រងពាណិជ្ជកម្ម

**អ្នកបច្ចេកទេសគាំទ្រព័ត៌មានវិទ្យា**
700-900$
បទពិសោធ ២-៤ ឆ្នាំ
ជំនាញ
- អេឡិចត្រូនិក
- គ្រប់គ្រងមូលដ្ឋានទិន្នន័យ និងបណ្តាញ

**វិស្វករផ្នែកប្រព័ន្ធអេឡិចត្រូនិក**
1000$ ឡើង
បទពិសោធ ៣-៥ ឆ្នាំ
ជំនាញ
- អេឡិចត្រូនិក
- សរសេរកម្មវិធីបញ្ជា និងវិភាគប្រព័ន្ធ

ចំនួនការងារសរុប
22,216

ក្រុមហ៊ុនកំពុងប្រកាសជ្រើសរើស (%នៃក្រុមហ៊ុនសរុប)
57.59 %

ការប៉ាន់ស្មានចំនួនជ្រើសរើសបុគ្គលិក


1,026

ការលំបាកក្នុងការជ្រើសរើសបុគ្គលិក (%នៃក្រុមហ៊ុនជ្រើសរើសបុគ្គលិក)
21.63 %

ក្រុមហ៊ុនផ្តល់ឱកាសឱ្យអ្នកគ្មានបទពិសោធន៍ (%នៃក្រុមហ៊ុនសរុប)
25.35 %

ឱកាសការងារក្នុងអនុវិស័យនេះ


3.04

រាជធានី/ខេត្ត ទាំង៣ ដែលមានតម្រូវការការងារខ្ពស់



កង្វះខាតជំនាញ (%នៃក្រុមហ៊ុនជ្រើសរើសបុគ្គលិក)
6.84 %

ក្រុមហ៊ុនដែលជួបបញ្ហាគម្លាតជំនាញ (%នៃក្រុមហ៊ុនសរុប)
21.58 %

# អនុវិស័យដឹកជញ្ជូន និងស្តុកទំនិញ

## មុខរបរដែលមានតម្រូវការខ្ពស់ ក្នុងកម្រិតជំនាញទាប




អនុវិស័យដឹកជញ្ជូន និងស្តុកទំនិញ
មុខរបរដែលមានតម្រូវការខ្ពស់ ក្នុងកម្រិតជំនាញមធ្យម
មុខជំនាញ
ISCED-F 2013
វិញ្ញាបនបត្រវិជ្ជាជីវៈ
សេវាដឹកជញ្ជូន 1041
សុខភាព និងសុវត្ថិភាពការងារ 1022
ពាណិជ្ជកម្ម និងរដ្ឋបាល 0410
អ្នកបើកបររថយន្តធុនតូច
$190-$280
បទពិសោធ 0-1 ឆ្នាំ
ជំនាញទន់
• ការគោរពពេលវេលា
• ការស្តាប់
សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ ១
សេវាដឹកជញ្ជូន 1041
យានយន្ត នាវា និងយន្តហោះ 0716
សុខភាព និងសុវត្ថិភាពការងារ 1022
អ្នកបើកបររថយន្តធុនធ្ងន់
$220-$320
បទពិសោធ 1-2 ឆ្នាំ
ជំនាញទន់
• ការងារជាក្រុម
• ជួសជុល
សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ ២
សេវាដឹកជញ្ជូន 1041
ការគ្រប់គ្រង និងរដ្ឋបាល 0413
ពាណិជ្ជកម្ម និងរដ្ឋបាល 0410
អ្នកសម្របសម្រួលការដឹកជញ្ជូន
$350-$500
បទពិសោធ 2-4 ឆ្នាំ
ជំនាញទន់
• ការដោះស្រាយបញ្ហា
• ទំនាក់ទំនង
សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ ៣
ទីផ្សារ និងការផ្សព្វផ្សាយពាណិជ្ជកម្ម 0414
សេវាដឹកជញ្ជូន 1041
ការគ្រប់គ្រង និងរដ្ឋបាល 0413
អ្នកត្រួតពិនិត្យប្រតិបត្តិការឃ្លាំងនិងដឹកជញ្ជូន
$400-$700
បទពិសោធ 2-4 ឆ្នាំ
ជំនាញទន់
• ចំណង់ចំណូលចិត្ត
• ការទំនាក់ទំនង
សញ្ញាបត្រជាន់ខ្ពស់ បច្ចេកទេស/ឯកទេស
ទីផ្សារ និងការផ្សព្វផ្សាយពាណិជ្ជកម្ម 0414
សេវាដឹកជញ្ជូន 1041
ពាណិជ្ជកម្ម និងរដ្ឋបាល 0413
ប្រធានផ្នែកគ្រប់គ្រងការផ្គត់ផ្គង់ និងចែកចាយ
$400-$700
បទពិសោធ 4-6 ឆ្នាំ
ជំនាញទន់
• ការដោះស្រាយបញ្ហា
• ការទំនាក់ទំនង
បរិញ្ញាបត្រឡើងទៅ
ទីផ្សារ និងការផ្សព្វផ្សាយពាណិជកម្ម 0414
សេវាកម្មដឹកជញ្ជូន 1041
ការគ្រប់គ្រង និងរដ្ឋបាល 0413
ប្រធានផ្នែកគ្រប់គ្រងការដឹកជញ្ជូន
$1200-$1800
បទពិសោធ 6-9 ឆ្នាំ
ជំនាញទន់
• ការរៀបចំផែនការយុទ្ធសាស្ត្រ
• ការយល់ដឹងស៊ីជម្រៅផ្នែកហិរញ្ញវត្ថុ
នាយកប្រតិបត្តិខ្សែសង្វាក់ផ្គត់ផ្គង់
$1500-1800
បទពិសោធ 8-10 ឆ្នាំ
ជំនាញទន់
• ភាពជាអ្នកដឹកនាំ
• ការចរចា
នាយកគ្រប់គ្រងភស្តុភារ និងដឹកជញ្ជូន
$1500-$2500
បទពិសោធ 10 ឆ្នាំឡើង
ជំនាញទន់
• ការគិតបែបយុទ្ធសាស្ត្រកម្រិតសហគ្រាស
• ក្សាទំនាក់ទំនងក្រុមប្រឹក្សាភិបាល

# អនុវិស័យដឹកជញ្ជូន និងស្តុកទំនិញ

## មុខរបរដែលមានតម្រូវការខ្ពស់ ក្នុងកម្រិតជំនាញខ្ពស់



# មុខរបរដទៃទៀតដែលមានតម្រូវការខ្ពស់ក្នុងអនុវិស័យដឹកជញ្ជូន និងស្តុកទំនិញ

## ជំនាញកម្រិតទាប (កម្រិត១)

### អ្នកនាំសារ និងអ្នកជញ្ជូនអីវ៉ាន់

200-250$
បទពិសោធ ១ ឆ្នាំ

ជំនាញ
- បើកបរយានយន្ត
- ការងារលេខាធិការ និងការិយាល័យ

### អ្នករៀបអីវ៉ាន់ដាក់លើធ្នើ

200-280$
បទពិសោធ ០-២ ឆ្នាំ

ជំនាញ
- ប្រើឧបករណ៍លើក និងជញ្ជូនទំនិញ
- សុខភាព និងសុវត្ថិភាពការងារ

### កម្មករកម្មន្តសាល (ផលិតកម្ម និងការកែច្នៃ)

300-350$
បទពិសោធ ០-២ ឆ្នាំ

ជំនាញ
- សេវាបំរើតាមផ្ទះ
- ផលិតកម្ម និងការកែច្នៃ

### អ្នកខ្ចប់វេចដោយដៃ

300-400$
បទពិសោធ ០-២ ឆ្នាំ

ជំនាញ
- ត្រួតពិនិត្យគុណភាព
- ផលិតកម្ម និងការកែច្នៃ

## ជំនាញកម្រិតមធ្យម (កម្រិត២)

### ការីម៉ាស៊ីនវេចខ្ចប់

210-250$
បទពិសោធ ១ ឆ្នាំ

ជំនាញ
- វាយនភណ្ឌ
- ប្រតិបត្តិការម៉ាស៊ីន និងដំណើរការផលិត

### ស្មៀនវាយបញ្ចូលទិន្នន័យ

250-280$
បទពិសោធ ៣ ឆ្នាំ

ជំនាញ
- កម្មវិធីកំព្យូទ័រ
- ការងារលេខាធិការ និងការិយាល័យ

### លេខាធិការ (ទូទៅ)

250-300$
បទពិសោធ ២ ឆ្នាំ

ជំនាញ
- កម្មវិធីកំព្យូទ័រ
- ការងារលេខាធិការ និងការិយាល័យ

### អ្នកទំនាក់ទំនងផ្នែកលក់តាមទូរស័ព្ទ

300-320$
បទពិសោធ ០-៣ ឆ្នាំ

ជំនាញ
- ទីផ្សារ
- គ្រប់គ្រងពាណិជ្ជកម្ម

## ជំនាញកម្រិតខ្ពស់ (កម្រិត៣ និង៤)

### អ្នកជំនាញផ្នែកផ្សព្វផ្សាយទីផ្សារ

350-450$
បទពិសោធ ៣-៥ ឆ្នាំ

ជំនាញ
- គ្រប់គ្រងពាណិជ្ជកម្ម
- គ្រប់គ្រង និងរដ្ឋបាល

### អ្នកបច្ចេកទេសគាំទ្រព័ត៌មានវិទ្យា

350-520$
បទពិសោធ ៣-៥ ឆ្នាំ

ជំនាញ
- អេឡិចត្រូនិក
- គ្រប់គ្រងមូលដ្ឋានទិន្នន័យ និងបណ្តាញ

### អ្នកបច្ចេកទេសវិស្វកម្ម (ផលិតកម្ម)

500-600$
បទពិសោធ ៣-៥ ឆ្នាំ

ជំនាញ
- អេឡិចត្រូនិក
- គ្រប់គ្រងផ្នែកជួសជុល

### នាយកផ្នែកទីផ្សារ

600-700$
បទពិសោធ ៣-៥ ឆ្នាំ

ជំនាញ
- សេដ្ឋកិច្ច និងគ្រប់គ្រង
- គ្រប់គ្រង និងរដ្ឋបាល

ចំនួនការងារសរុប



24,681

ក្រុមហ៊ុនកំពុងប្រកាសជ្រើសរើស (%នៃក្រុមហ៊ុនសរុប)



60.07 %

ការប៉ាន់ស្មានចំនួនជ្រើសរើសបុគ្គលិក




2,119

ការលំបាកក្នុងការជ្រើសរើសបុគ្គលិក (%នៃក្រុមហ៊ុនជ្រើសរើសបុគ្គលិក)



28.37 %

ក្រុមហ៊ុនផ្តល់ឱកាសឱ្យអ្នកគ្មានបទពិសោធន៍ (%នៃក្រុមហ៊ុនសរុប)



29.06 %

ឱកាសការងារក្នុងអនុវិស័យនេះ




3.19

រាជធានី/ខេត្ត ទាំង៣ ដែលមានតម្រូវការការងារខ្ពស់




កង្វះខាតជំនាញ (%នៃក្រុមហ៊ុនជ្រើសរើសបុគ្គលិក)



20.96 %

ក្រុមហ៊ុនដែលជួបបញ្ហាគម្លាតជំនាញ (%នៃក្រុមហ៊ុនសរុប)



15.38 %

# អនុវិស័យសំណង់

## មុខរបរដែលមានតម្រូវការខ្ពស់ ក្នុងកម្រិតជំនាញទាប




អនុវិស័យសំណង់
មុខរបរដែលមានតម្រូវការខ្ពស់ ក្នុងកម្រិតជំនាញមធ្យម
មុខជំនាញ
ISCED-F 2013
វិញ្ញាបនបត្រវិជ្ជាជីវៈ
សំណង់ និងវិស្វកម្មស៊ីវិល 0732
មេកានិច និងជាងលោហៈ 0715
សុខភាព និងសុវត្ថិភាពការងារ 1022
កម្មករសំណង់
$190-$280
បទពិសោធ
1-2 ឆ្នាំ
ជំនាញទន់
• ការស្តាប់
• ការធ្វើការជាក្រុម
សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ ១
ពាណិជ្ជកម្ម និងរដ្ឋបាល 0410
ការគ្រប់គ្រង និងរដ្ឋបាល 0413
សំណង់ និងវិស្វកម្មស៊ីវិល 0732
ជំនួយការរដ្ឋបាលការដ្ឋាន
$220-$350
បទពិសោធ
1-2 ឆ្នាំ
ជំនាញទន់
• ការងារជាក្រុម
• ការយកចិត្តទុកដាក់
សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ ២
សំណង់ និងវិស្វកម្មស៊ីវិល 0732
មេកានិច និងជាងលោហៈ 0715
សុខភាព និងសុវត្ថិភាពការងារ 1022
ស្មៀនការិយាល័យទូទៅ
300-$450
បទពិសោធ
2-4 ឆ្នាំ
ជំនាញទន់
• ដោះស្រាយបញ្ហា
• ការទំនាក់ទំនង
សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ ៣
ពាណិជ្ជកម្ម និងរដ្ឋបាល 0410
ការគ្រប់គ្រង និងរដ្ឋបាល 0413
សំណង់ និងវិស្វកម្មស៊ីវិល 0732
មន្ត្រីលទ្ធកម្មការដ្ឋាន
$350-$500
បទពិសោធ
4-6 ឆ្នាំ
ជំនាញទន់
• ភាពជាអ្នកដឹកនាំ
• ការគ្រប់គ្រងជម្លោះ
សញ្ញាបត្រជាន់ខ្ពស់ បច្ចេកទេស/ឯកទេស
សំណង់ និងវិស្វកម្មស៊ីវិល 0732
ការគ្រប់គ្រង និងរដ្ឋបាល 0413
ពាណិជ្ជកម្ម និងរដ្ឋបាល 0410
នាយកគ្រប់គ្រងវិស្វកម្មស៊ីវិល
$600-$850
បទពិសោធ
6 ឆ្នាំ
ជំនាញទន់
• ផែនការយុទ្ធសាស្ត្រ
• ការចរចា
បរិញ្ញាបត្រឡើងទៅ
សំណង់ និងវិស្វកម្មស៊ីវិល 0732
ការគ្រប់គ្រង និងរដ្ឋបាល 0413
ពាណិជ្ជកម្ម និងរដ្ឋបាល 0410
ប្រធានផ្នែកគ្រប់គ្រងលើគម្រោងសាងសង់
$1500-$2500
បទពិសោធន៍
10 ឆ្នាំឡើង
ជំនាញទន់
• ការសម្រេចចិត្តយុទ្ធសាស្ត្រ
• ការរៀបចំផែនការគម្រោង

# អនុវិស័យសំណង់

## មុខរបរដែលមានតម្រូវការខ្ពស់ ក្នុងកម្រិតជំនាញខ្ពស់

### វិញ្ញាបនបត្រវិជ្ជាជីវៈ

| មុខជំនាញ | ISCED-F 2013 |
|---|---|
| សំណង់ និងវិស្វកម្មស៊ីវិល | 0732 |
| អគ្គិសនី និងថាមពល | 0713 |
| ការគ្រប់គ្រង និងរដ្ឋបាល | 0413 |

**អ្នកថែទាំអគារ**
- $190-$280
- បទពិសោធ 0-1ឆ្នាំ
- ជំនាញទន់:
  - ការងារជាក្រុម
  - ការយកចិត្តទុកដាក់

### សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ ១

| មុខជំនាញ | ISCED-F 2013 |
|---|---|
| អគ្គិសនី និងថាមពល | 0713 |
| បច្ចេកវិទ្យា ការពារបរិស្ថាន | 0712 |
| សំណង់ និងវិស្វកកម្មស៊ីវិល | 0732 |

**ជាងអគ្គិសនី**
- $220-$350
- បទពិសោធ 1-2ឆ្នាំ
- ជំនាញទន់:
  - ការផ្ដោតអារម្មណ៍
  - ការធ្វើការជាក្រុម

### សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ ២

| មុខជំនាញ | ISCED-F 2013 |
|---|---|
| សំណង់ និងវិស្វកម្មស៊ីវិល | 0732 |
| ស្ថាបត្យកម្ម និងការរៀបចំក្រុង | 0731 |
| ការគ្រប់គ្រង និងរដ្ឋបាល | 0413 |

**ជាងជួសជុលអគ្គិសនីនៅអគារ**
- $350-$500
- បទពិសោធ 1-2 ឆ្នាំ
- ជំនាញទន់:
  - ការរៀបចំផែនការគម្រោង
  - ការចរចា

### សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ ៣

| មុខជំនាញ | ISCED-F 2013 |
|---|---|
| សំណង់ និងវិស្វកម្មស៊ីវិល | 0732 |
| ការគ្រប់គ្រង និងរដ្ឋបាល | 0413 |
| ពាណិជ្ជកម្មនិងរដ្ឋបាល | 0410 |

**ជំនួយការអ្នកគ្រប់គ្រងប្រតិបត្តិការសំណង់**
- $450-$650
- បទពិសោធ 3 ឆ្នាំឡើង
- ជំនាញទន់:
  - ការធ្វើផែនការយុទ្ធសាស្ត
  - ការចរចា

### សញ្ញាបត្រជាន់ខ្ពស់ បច្ចេកទេស/ឯកទេស

| មុខជំនាញ | ISCED-F 2013 |
|---|---|
| ស្ថាបត្យកម្ម និងការរៀបចំក្រុង | 0414 |
| ការគ្រប់គ្រង និងរដ្ឋបាល | 0413 |
| សំណង់ និងវិស្វកម្មស៊ីវិល | 0732 |

**អ្នកគ្រប់គ្រងប្រតិបត្តិការសំណង់**
- $600-$700
- បទពិសោធ 4 ឆ្នាំឡើង
- ជំនាញទន់:
  - ការធ្វើផែនការយុទ្ធសាស្ត្រ
  - ការចរចា

### បរិញ្ញាបត្រឡើងទៅ

| មុខជំនាញ | ISCED-F 2013 |
|---|---|
| សំណង់ និងវិស្វកម្មស៊ីវិល | 0732 |
| ការគ្រប់គ្រង និងរដ្ឋបាល | 0413 |
| ពាណិជ្ជកម្មនិងរដ្ឋបាល | 0410 |

**ប្រធានផ្នែកគ្រប់គ្រងលើគម្រោងសាងសង់**
- $1500 ឡើង
- បទពិសោធ 8 ឆ្នាំឡើង
- ជំនាញទន់:
  - ចក្ខុវិស័យសហគ្រាស
  - ការគ្រប់គ្រងហានិភ័យ

## មុខរបរដទៃទៀតដែលមានតម្រូវការខ្ពស់ក្នុងអនុវិស័យសំណង់

### ជំនាញកម្រិតទាប (កម្រិត១)

**ជាងរៀបឥដ្ឋ**
- 210-250$
- បទពិសោធ ០-១ ឆ្នាំ
- ជំនាញ
  - សំណង់
  - សុខភាព និងសុវត្ថិភាពការងារ

**អ្នករៀបអីវ៉ាន់ដាក់លើធ្នើ**
- 200-280$
- បទពិសោធ ០-២ ឆ្នាំ
- ជំនាញ
  - ប្រើឧបករណ៍លើក និងជញ្ជូនទំនិញ
  - សុខភាព និងសុវត្ថិភាពការងារ

**អ្នកនាំសារ និងអ្នកជញ្ជូនអីវ៉ាន់**
- 200-250$
- បទពិសោធ ០-២ ឆ្នាំ
- ជំនាញ
  - បើកបរយានយន្ត
  - ការងារលេខាធិការ និងការិយាល័យ

**អ្នកសម្អាតអនាម័យក្នុងអាគារ**
- 200-250$
- បទពិសោធ ០-៣ ឆ្នាំ
- ជំនាញ
  - សេវាបំរើតាមផ្ទះ
  - ភាពហ្មត់ចត់ និងស្មោះត្រង់

### ជំនាញកម្រិតមធ្យម (កម្រិត២)

**អ្នកបើកបររថយន្តធុនធ្ងន់**
- 330-550$
- បទពិសោធ ៣ ឆ្នាំ
- ជំនាញ
  - មេកានិក
  - បើកបរយានយន្ត

**អ្នកផ្គុំដំឡើងដទៃទៀត មិនបានចាត់ថ្នាក់**
- 250-320$
- បទពិសោធ ១ ឆ្នាំ
- ជំនាញ
  - មេកានិក
  - អេឡិចត្រូនិក

**លេខាធិការ (ទូទៅ)**
- 250-300$
- បទពិសោធ ២ ឆ្នាំ
- ជំនាញ
  - កម្មវិធីកំព្យូទ័រ
  - ការងារលេខាធិការ និងការិយាល័យ

**ស្មៀនផ្នែកគណនេយ្យ និងបញ្ជី**
- 300-400$
- បទពិសោធ ៣ ឆ្នាំ
- ជំនាញ
  - គណនេយ្យ និងពន្ធដារ
  - ហិរញ្ញវត្ថុ និងធនាគារ

### ជំនាញកម្រិតខ្ពស់ (កម្រិត៣ និង៤)

**អ្នកជំនាញផ្នែកផ្សព្វផ្សាយទីផ្សារ**
- 400-600$
- បទពិសោធ ៣-៥ ឆ្នាំ
- ជំនាញ
  - វិស្វកម្មកម្មវិធីកំព្យូទ័រ និងពហុមេឌា
  - បច្ចេកទេសaudio និងប្រព័ន្ធផ្សព្វផ្សាយ

**នាយកផ្នែកទីផ្សារ**
- 900-1200$
- បទពិសោធ ៥ ឆ្នាំ
- ជំនាញ
  - សេដ្ឋកិច្ច និងគ្រប់គ្រង
  - គ្រប់គ្រង និងរដ្ឋបាល

**អ្នកបច្ចេកទេសគាំទ្រព័ត៌មានវិទ្យា**
- 330-520$
- បទពិសោធ ០-២ ឆ្នាំ
- ជំនាញ
  - កម្មវិធីកំព្យូទ័រ
  - គ្រប់គ្រងមូលដ្ឋានទិន្នន័យ និងបណ្តាញ

**បុគ្គលិកផ្គត់ផ្គង់ ឬលទ្ធកម្ម**
- 500-550$
- បទពិសោធ ៣-៥ ឆ្នាំ
- ជំនាញ
  - ទីផ្សារ
  - គ្រប់គ្រងពាណិជ្ជកម្ម

ចំនួនការងារសរុប: 34,992

ក្រុមហ៊ុនកំពុងប្រកាសជ្រើសរើស (%នៃក្រុមហ៊ុនសរុប): 39.32 %

ការប៉ាន់ស្មានចំនួនជ្រើសរើសបុគ្គលិក: 2,852

ការលំបាកក្នុងការជ្រើសរើសបុគ្គលិក (%នៃក្រុមហ៊ុនជ្រើសរើសបុគ្គលិក): 6.96 %

ក្រុមហ៊ុនផ្តល់ឱកាសឱ្យអ្នកគ្មានបទពិសោធន៍ (%នៃក្រុមហ៊ុនសរុប): 14.76 %

ឱកាសការងារក្នុងអនុវិស័យនេះ: 2.86




កង្វះខាតជំនាញ (%នៃក្រុមហ៊ុនជ្រើសរើសបុគ្គលិក): 10.80 %

ក្រុមហ៊ុនដែលជួបបញ្ហាគម្លាតជំនាញ (%នៃក្រុមហ៊ុនសរុប): 7.32 %

រាជធានី/ខេត្ត ទាំង៣ ដែលមានតម្រូវការការងារខ្ពស់



# អនុវិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរនិងកាបូប

## មុខរបរដែលមានតម្រូវការខ្ពស់ ក្នុងកម្រិតជំនាញទាប



# អនុវិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប

## មុខរបរដែលមានតម្រូវការខ្ពស់ ក្នុងកម្រិតជំនាញមធ្យម



# អនុវិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប

## មុខរបរដែលមានតម្រូវការខ្ពស់ ក្នុងកម្រិតជំនាញខ្ពស់

